រដ្ឋសភា
ចូល
លេខ ១៩៤៤
ថ្ងៃទី ០២/០៧ ឆ្នាំ ២០២០ ម៉ោង ០៩:៣០
បញ្ជូនទៅ T.ស

# ព្រះរាជក្រម

នស/រកម/០៦២០/០១៩

## យើង

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្ដម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ដ្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្ដិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ដ្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយរបស់សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី៤ ហើយដែលមានសេចក្ដីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការប្រឆាំងហិរញ្ញប្បទាន
# ដល់ការរីកសាយភាយអាវុធមហាប្រល័យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .–** គោលបំណង

ច្បាប់នេះមានគោលបំណងធានាការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយកំណត់អំពីវិធានការបង្ការ ទប់ស្កាត់ បង្ក្រាប និងលុបបំបាត់ហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

**មាត្រា២ .–** វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរាល់សកម្មភាពហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .–** និយមន័យ

វាក្យស័ព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យដូចតទៅ៖

១- ទ្រព្យសម្បត្តិ សំដៅដល់មូលនិធិ កម្មសិទ្ធិ ធនធានហិរញ្ញវត្ថុ និងធនធានសេដ្ឋកិច្ចគ្រប់ប្រភេទ មិនថារូបិយឬអរូបិយ ចលនៈឬអចលនៈ កំពុងមានក្នុងពេលបច្ចុប្បន្នឬអាចមាននាពេលអនាគត ទោះទទួលបានតាមវិធីណាក៏ដោយឱ្យតែស្ថិតក្នុងប្រភេទដូចខាងក្រោម៖

ក- សាច់ប្រាក់។

ខ- រូបិយប័ណ្ណនិមិត្តឬរូបិយប័ណ្ណឌីជីថល រួមទាំង រូបិយប័ណ្ណគ្រីបតូ។

គ- ឥណទាន មូលប្បទានប័ត្រទេសចរណ៍ មូលប្បទានប័ត្រធនាគារ អាណត្តិប្រៃសណីយ៍។

ឃ- លោហធាតុមានតម្លៃ និងត្បូងថ្មមានតម្លៃ។

ង- អចលនវត្ថុ ចលនវត្ថុ និងនាវា។

ច- ភាគហ៊ុន មូលប័ត្រ សញ្ញាបណ្ណ និងរូបិយាណត្តិ( Bill of exchange or draft )។

ឆ- សិទ្ធិលក់ឡាយឡុង លិខិតធានា លិខិតធានាលើការអនុវត្តកិច្ចសន្យា និងការសន្យាផ្តល់ហិរញ្ញវត្ថុផ្សេងទៀត។

ជ- លិខិតឥណទាន អញ្ញត្តបត្រ( Bill of lading ) បណ្ណដឹកជញ្ជូន វិក័យប័ត្រលក់។

ឈ- លិខិតុបករណ៍ផ្តល់ហិរញ្ញប្បទានសម្រាប់ការនាំចេញ។

ញ- ធនធានធម្មជាតិ។

ដ- ធនធានកម្លាំងពលកម្ម ដូចជាសេវាកម្មយានិក។

ឋ- ធនធានសេដ្ឋកិច្ចផ្សេងទៀតដែលអាចប្រើប្រាស់ដើម្បីទទួលបានមូលនិធិទំនិញឬសេវាកម្ម។

ឌ- ឯកសារឬលិខិតុបករណ៍គតិយុត្តគ្រប់ទម្រង់ រួមទាំងប្រភេទអេឡិចត្រូនិកឬឌីជីថល ជាភស្តុតាងបញ្ជាក់កម្មសិទ្ធិឬផលប្រយោជន៍ ឬសិទ្ធិទាមទារទ្រព្យ។

ឍ- ការប្រាក់ ភាគលាភ ចំណូល ឬតម្លៃកើនឡើងពីឬរកបានពីឬបង្វែរមកពីទ្រព្យ។

២- បុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី សំដៅដល់រូបវន្តបុគ្គលឬអង្គភាពដែលកំណត់ឈ្មោះដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សាស្របតាមមាត្រា៤នៃច្បាប់នេះឬដោយតុលាការស្របតាមមាត្រា៥នៃច្បាប់នេះ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL * ព្រះបរមរាជវាំង

៣- **អង្គភាព** សំដៅដល់នីតិបុគ្គល អង្គភាពមិនមែនសាជីវកម្ម ក្រុម សមាគម អង្គការ គ្រឹះស្ថាននិងការចងក្រងនានា។

៤- **ការបង្កកទ្រព្យសម្បត្តិ** សំដៅដល់ការទប់ស្កាត់ការលក់ ការផ្ដត់ផ្ដង់ ភតិសន្យា ការផ្ទេរ ការបំប្លែង ការធ្វើមតិកឬអនុប្បទាន ការចល័ត ឬការប្រើប្រាស់ទ្រព្យ។

៥- **អាវុធមហាប្រល័យ** សំដៅដល់អាវុធផ្ទុះអាតូមិកឬនុយក្លេអ៊ែរ អាវុធសម្ភារៈវិទ្យុសកម្ម អាវុធគីមី និងអាវុធជីវសាស្ត្រដែលអាចសម្លាប់ ឬបង្កមហន្តរាយដល់មនុស្សឬសត្វពាហនៈ ព្រមទាំងអាវុធផ្សេងទៀត ដែលនឹងត្រូវបានផលិតនាពេលអនាគតដែលមានលក្ខណៈបង្កនូវផលបំផ្លិចបំផ្លាញដូចនឹងគ្រាប់បែកអាតូមិកឬនុយក្លេអ៊ែរ ឬអាវុធដទៃទៀតដូចដែលបានរៀបរាប់ខាងលើ។

៦- **អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា** សំដៅដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដូចមានចែងក្នុងច្បាប់ស្ដីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងដែលបំពេញមុខងារបន្ថែមដូចមានចែងក្នុងច្បាប់នេះ។

៧- **ក្រសួង ស្ថាប័នត្រួតពិនិត្យ** សំដៅដល់ធនាគារជាតិនៃកម្ពុជា គណៈកម្មការមូលបត្រកម្ពុជា និងក្រសួង ស្ថាប័នផ្សេងទៀត ដែលត្រួតពិនិត្យលើបុគ្គលរាយការណ៍។

## ជំពូកទី២
## ការដាក់ឈ្មោះក្នុងបញ្ជីនិងការបង្កកទ្រព្យសម្បត្តិ

**មាត្រា៤ .-** ការដាក់ឈ្មោះក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ

ក្រោយពីបានទទួលសេចក្ដីសម្រេចចិត្តដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ជូនដោយគ្មានបង្អង់នូវសេចក្ដីសម្រេចចិត្តដាក់ឈ្មោះបុគ្គលឬអង្គភាពជាប់ក្នុងបញ្ជីដូចមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះទៅក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនឯកសារទាំងនោះទៅតុលាការដោយគ្មានបង្អង់ ដើម្បីស្នើសុំសេចក្ដីសម្រេចបង្កកទ្រព្យសម្បត្តិទាំងអស់ដូចខាងក្រោម៖

ក- ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬគ្រប់គ្រងដោយបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី ទោះមួយផ្នែកឬទាំងស្រុង ដោយផ្ទាល់ឬដោយប្រយោលក្ដី ហើយមិនមែនត្រឹមតែជាទ្រព្យសម្បត្តិដែលអាចជាប់ជាមួយសកម្មភាព ផែនការទុច្ចរិត ឬការគំរាមកំហែងជាក់លាក់នោះទេ។

ខ- ទ្រព្យសម្បត្តិរបស់បុគ្គលឬអង្គភាពតំណាង ឬស្ថិតក្រោមការដឹកនាំផ្ទាល់ពីបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី។

គ- ទ្រព្យសម្បត្តិបង្វែរមកពី ឬរកបានមកពីទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងវាក្យខណ្ឌ(ក) និង(ខ)។

ឃ- នាវាជាប់ឈ្មោះក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះអនុលោមតាមសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

សេចក្ដីសម្រេចបង្កកទ្រព្យសម្បត្តិចេញដោយតុលាការពុំមានរយៈពេលកំណត់ឡើយ លើកលែងតែសេចក្ដីសម្រេចនោះត្រូវបានលុបចោល។

**មាត្រា៥ .‒** ការដាក់ឈ្មោះក្នុងបញ្ជីដោយតុលាការ

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឬព្រះរាជអាជ្ញាអមសាលាដំបូងដើម្បីស្នើទៅតុលាការដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិ។

តុលាការត្រូវចេញសេចក្តីសម្រេចដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិរបស់ពួកគេក្នុងករណីមានមូលដ្ឋានសមហេតុផលនិងជឿជាក់ថាបុគ្គលឬអង្គភាពនោះត្រូវនឹងលក្ខខណ្ឌដូចមានចែងលម្អិតក្នុងកថាខណ្ឌ៣២នៃសេចក្តីសម្រេចចិត្តលេខ២២៧០ របស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិនិងសេចក្តីសម្រេចចិត្តបន្តបន្ទាប់។

សេចក្តីសម្រេចបង្កកទ្រព្យសម្បត្តិចេញដោយតុលាការត្រូវអនុវត្តចំពោះទ្រព្យសម្បត្តិដូចខាងក្រោម៖

ក- ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិឬគ្រប់គ្រងដោយបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី ទោះមួយផ្នែកឬទាំងស្រុង ដោយផ្ទាល់ឬដោយប្រយោលក្តី ហើយមិនមែនត្រឹមតែជាទ្រព្យសម្បត្តិដែលអាចជាប់ជាមួយសកម្មភាព ផែនការទុច្ចរិត ឬការគំរាមកំហែងជាក់លាក់នោះទេ។

ខ- ទ្រព្យសម្បត្តិរបស់បុគ្គលឬអង្គភាពតំណាងឬស្ថិតក្រោមការដឹកនាំផ្ទាល់ពីបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី។

គ- ទ្រព្យសម្បត្តិបង្វែរមកពីឬកេបានមកពីទ្រព្យសម្បត្តិ ដែលបានកំណត់នៅក្នុងវាក្យខណ្ឌ(ក) និង(ខ)។

ឃ- នាវាជាប់ឈ្មោះក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ អនុលោមតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិដូចមានចែងនៅក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ។

សេចក្តីសម្រេចដាក់ឈ្មោះក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិ ចេញដោយតុលាការពុំមានរយៈពេលកំណត់ឡើយ លើកលែងតែសេចក្តីសម្រេចនោះត្រូវបានលុបចោល។

**មាត្រា៦ .‒** ការបង្កកទ្រព្យសម្បត្តិ

រាល់បុគ្គលឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិដែលត្រូវបានបង្កកតាមអំណាចសេចក្តីសម្រេចរបស់តុលាការដូចបានកំណត់ក្នុងមាត្រា៤ឬមាត្រា៥នៃច្បាប់នេះ ត្រូវបង្កកទ្រព្យសម្បត្តិទាំងនោះដោយគ្មានបង្អង់និងដោយគ្មានជូនដំណឹងជាមុនឡើយ។

## ជំពូកទី៣

## ការស្នើសុំដកឈ្មោះចេញពីបញ្ជីនិងការអនុញ្ញាតឱ្យប្រើប្រាស់ទ្រព្យសម្បត្តិ

**មាត្រា៧ .‒** ការស្នើសុំទៅក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិដកឈ្មោះចេញពីបញ្ជី

បុគ្គលឬអង្គភាពណាដែលទទួលរងផលប៉ះពាល់ដោយសេចក្តីសម្រេចចិត្តដាក់ឈ្មោះក្នុងបញ្ជីដូចមានចែងក្នុងមាត្រា៤នៃច្បាប់នេះ អាចដាក់ពាក្យបណ្តឹងសុំដកឈ្មោះចេញពីបញ្ជីដូចមានចែងក្នុងឧបសម្ព័ន្ធនៃច្បាប់នេះ ទៅក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ ដើម្បីពិនិត្យសេចក្តីសម្រេចនេះឡើងវិញ។

នៅពេលក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះសម្រេចដកឈ្មោះបុគ្គលឬអង្គភាពចេញពីបញ្ជីរួចហើយ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិត្រូវបញ្ជូនដោយគ្មានបង្អង់នូវសេចក្តីសម្រេចចិត្តដកឈ្មោះបុគ្គលឬអង្គភាពចេញពីបញ្ជីទៅក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌ត្រូវចាត់បញ្ជូនឯកសារទាំងនោះដោយគ្មានបង្អង់ទៅតុលាការដើម្បីស្នើសុំតុលាការចេញសេចក្តីសម្រេចលុបចោលការបង្កកទ្រព្យសម្បត្តិ។

**មាត្រា៨ .- ការស្នើសុំទៅតុលាការដកឈ្មោះចេញពីបញ្ជីនិងលុបចោលការបង្កកទ្រព្យសម្បត្តិ**

បុគ្គលឬអង្គភាពណាដែលទទួលរងផលប៉ះពាល់ដោយសេចក្តីសម្រេចរបស់តុលាការដាក់ឈ្មោះក្នុងបញ្ជីនិងបង្កកទ្រព្យសម្បត្តិដូចមានចែងក្នុងមាត្រា៥នៃច្បាប់នេះ អាចដាក់ពាក្យបណ្តឹងទៅតុលាការសុំដកឈ្មោះចេញពីបញ្ជីនិងលុបចោលការបង្កកទ្រព្យសម្បត្តិទៅតាមនីតិវិធីច្បាប់កំណត់។

នៅពេលតុលាការចេញសេចក្តីសម្រេចដកឈ្មោះចេញពីបញ្ជី និងលុបចោលការបង្កកទ្រព្យសម្បត្តិរួចហើយ តុលាការត្រូវជូនដំណឹងទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដើម្បីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិជូនដំណឹងទៅក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ អំពីការសម្រេចដកឈ្មោះបុគ្គលឬអង្គភាពចេញពីបញ្ជីនិងការលុបចោលការបង្កកទ្រព្យសម្បត្តិ។

**មាត្រា៩ .- ការអនុញ្ញាតឱ្យប្រើប្រាស់ទ្រព្យសម្បត្តិបង្កក**

បុគ្គលឬអង្គភាពដែលកាន់កាប់ទ្រព្យសម្បត្តិបង្កកអាចត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិបង្កកបាន។

ការប្រើប្រាស់និងការចាត់ចែងទ្រព្យសម្បត្តិបង្កកត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៤
## ការហាមឃាត់និងភាតព្វកិច្ច

**មាត្រា១០ .- ការហាមឃាត់មិនឱ្យប្រើប្រាស់ទ្រព្យសម្បត្តិ**

គ្មានបុគ្គលឬអង្គភាពណាមួយដែលស្ថិតក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជាអាចប្រគល់ទ្រព្យសម្បត្តិទាំងអស់ឬមួយផ្នែក ទោះដោយផ្ទាល់ឬដោយប្រយោលក្តី ឬអាចប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះជាផលប្រយោជន៍ដល់បុគ្គលឬអង្គភាពដូចខាងក្រោម៖

ក- បុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី។

ខ- បុគ្គលឬអង្គភាពដែលជាកម្មសិទ្ធិឬគ្រប់គ្រង ដោយផ្ទាល់ឬដោយប្រយោលដោយបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី។

គ- បុគ្គលឬអង្គភាពជាតំណាង ឬស្ថិតក្រោមការដឹកនាំផ្ទាល់របស់បុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី ឬបុគ្គលឬអង្គភាពដែលជាកម្មសិទ្ធិឬការគ្រប់គ្រងរបស់បុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី។

[illegible]ករណ៍ដូចមានចែងក្នុងមាត្រា១១នៃច្បាប់នេះអាចអនុញ្ញាតឱ្យយកប្រាក់ដែលបានទូទាត់ឬចំណូលផ្សេងទៀតដែលកើតចេញពីកាតព្វកិច្ចនៃកិច្ចសន្យាទៅដាក់បញ្ចូលបន្ថែមក្នុងគណនីបង្កក ក្នុងករណី[illegible]ទាត់ឬចំណូលទាំងនោះត្រូវបានបង្កកដូចគ្នា។

**មាត្រា១១ .- បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ដែលមានកំណត់នៅក្នុងច្បាប់នេះមានដូចខាងក្រោម៖

ក- ធនាគារ រួមទាំងសាខារបស់ធនាគារបរទេស។

ខ- គ្រឹះស្ថានហិរញ្ញវត្ថុមិនមែនធនាគារ រួមមានក្រុមហ៊ុនជើងសារមូលបត្រនិងក្រុមហ៊ុនធានារ៉ាប់រង។

គ- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ។

ឃ- សហករណ៍ឥណទាន។

ង- ក្រុមហ៊ុនកតិសន្យា មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ។

ច- អាជីវកម្មប្តូរប្រាក់។

ឆ- សេវាផ្ទេរប្រាក់។

ជ- បរធនបាលកិច្ច។

ឈ- ភ្នាក់ងារ ក្រុមហ៊ុន អ្នកអភិវឌ្ឍន៍អចលនទ្រព្យ អគារ និងដីធ្លី។

ញ- ឈ្មួញលោហធាតុ ត្បូងថ្មមានតម្លៃ។

ដ- ការិយាល័យប្រៃសណីយ៍ ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់។

ឋ- មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិនៅពេលដែលអ្នកទាំងនោះរៀបចំឬធ្វើប្រតិបត្តិការទាក់ទងទៅនឹងសកម្មភាពបម្រើឱ្យអតិថិជនរបស់ខ្លួន។

ឌ- កាស៊ីណូនិងគ្រឹះស្ថានល្បែងភ្នាល់ផ្សេងៗ។

ឍ- អង្គការមិនមែនរដ្ឋាភិបាល និងអង្គការមូលនិធិធ្វើសកម្មភាពអាជីវកម្មនិងរៃអង្គាសមូលនិធិ។

ណ- បុគ្គលឬអង្គភាពផ្សេងទៀត កំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់នេះ។

**មាត្រា១២ .- កាតព្វកិច្ចរាយការណ៍របស់បុគ្គលរាយការណ៍**

បុគ្គលរាយការណ៍ដែលបានបង្កកទ្រព្យសម្បត្តិស្របតាមមាត្រា៦នៃច្បាប់នេះ ត្រូវរាយការណ៍ក្នុងរយៈពេលមិនលើសពី៣(បី)ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិនិងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

បុគ្គលរាយការណ៍ដែលត្រូវបានស្នើឱ្យប្រគល់ទ្រព្យសម្បត្តិទៅឱ្យបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីដែលផ្ទុយនឹងមាត្រា១០នៃច្បាប់នេះ ត្រូវរាយការណ៍សំណើសុំនេះដោយគ្មានបង្អង់ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

បុគ្គលរាយការណ៍ត្រូវដាក់របាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ហើយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាត្រូវថតចម្លងរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិជូនក្រសួងយុត្តិធម៌។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

បុគ្គលរាយការណ៍ដែលបានធ្វើរបាយការណ៍ស្របតាមមាត្រានេះត្រូវផ្ដល់ព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងរបាយការណ៍នេះឱ្យបានឆាប់រហ័សតាមសំណើសុំរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាឬក្រសួងយុត្តិធម៌។

**មាត្រា១៣ .–** កាតព្វកិច្ចរាយការណ៍របស់បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍

បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ដែលបានបង្កកទ្រព្យសម្បត្តិស្របតាមមាត្រា៦នៃច្បាប់នេះ ត្រូវរាយការណ៍ក្នុងរយៈពេលមិនលើសពី៣(បី)ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិនិងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកទៅក្រសួងយុត្តិធម៌។

បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ដែលត្រូវបានស្នើឱ្យប្រគល់ទ្រព្យសម្បត្តិទៅឱ្យបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីដែលផ្ទុយនឹងមាត្រា១០នៃច្បាប់នេះ ត្រូវរាយការណ៍សំណើសុំនេះដោយគ្មានបង្អង់ទៅក្រសួងយុត្តិធម៌។

បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ត្រូវដាក់របាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិទៅក្រសួងយុត្តិធម៌ ហើយក្រសួងយុត្តិធម៌ត្រូវថតចម្លងរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ ក្រសួងយុត្តិធម៌អាចកំណត់អំពីទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិ។

បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ដែលបានធ្វើរបាយការណ៍ស្របតាមមាត្រានេះត្រូវផ្ដល់ព័ត៌មានផ្សេងទៀតដែលទាក់ទងនឹងរបាយការណ៍នេះឱ្យបានឆាប់រហ័សតាមសំណើសុំរបស់ក្រសួងយុត្តិធម៌ឬអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។

## ជំពូកទី៥
## ការរឹបអូសទ្រព្យសម្បត្តិបង្កក

**មាត្រា១៤ .–** ការរឹបអូសទ្រព្យសម្បត្តិបង្កក

ការរឹបអូសទ្រព្យសម្បត្តិដែលត្រូវបានបង្កកត្រូវអនុវត្តទៅតាមសេចក្ដីសម្រេចរបស់តុលាការតាមសំណើពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឬពីព្រះរាជអាជ្ញាអមសាលាដំបូង បន្ទាប់ពីទទួលបានអធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឬផ្អែកតាមសំណើពីអ្នកកាន់កាប់ទ្រព្យសម្បត្តិដែលត្រូវបានបង្កក។

តុលាការអាចចេញសេចក្ដីសម្រេចបង្គាប់ឱ្យរឹបអូសទ្រព្យសម្បត្តិដែលត្រូវបានបង្កក ប្រសិនបើមានហានិភ័យសមហេតុសមផលបង្ហាញថាទ្រព្យសម្បត្តិនោះអាចនឹងបាត់បង់។

តុលាការអាចចាត់តាំងអ្នកគ្រប់គ្រងមើលថែទាំទ្រព្យសម្បត្តិដែលបានរឹបអូស។

ទ្រព្យសម្បត្តិដែលបានរឹបអូសស្របតាមមាត្រានេះ ត្រូវរក្សាទុកដោយអ្នកគ្រប់គ្រងដែលតែងតាំងដោយតុលាការ រហូតដល់ពេលទ្រព្យសម្បត្តិនោះលែងជាកម្មវត្ថុនៃការបង្កកទ្រព្យសម្បត្តិដូចមានកំណត់ក្នុងមាត្រា៤ ឬមាត្រា៥នៃច្បាប់នេះ។

## ជំពូកទី៦
## យន្តការគ្រប់គ្រង

**មាត្រា១៥ .–** គណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ

ត្រូវបានបង្កើតគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិ ដើម្បីទទួលបន្ទុករៀបចំដាក់ចេញនូវគោលនយោបាយ ដឹកនាំ និងសម្របសម្រួលការអនុវត្តច្បាប់នេះ។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៦ .- ការតាមដាននិងត្រួតពិនិត្យ**

ក្រសួង ស្ថាប័នត្រួតពិនិត្យត្រូវតាមដានបុគ្គលរាយការណ៍ស្ថិតក្រោមការត្រួតពិនិត្យរបស់ខ្លួនដើម្បីធានាការគោរពតាមច្បាប់នេះ។

ក្រសួងយុត្តិធម៌ត្រូវតាមដានពីអនុលោមភាពនិងផ្សព្វផ្សាយច្បាប់នេះដល់បុគ្គលឬអង្គភាពផ្សេងទៀតដែលមិនមែនជាបុគ្គលរាយការណ៍។

**មាត្រា១៧ .- ការបង្ហាញព័ត៌មាន**

ក្រសួងយុត្តិធម៌ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា និងក្រសួង ស្ថាប័នត្រួតពិនិត្យ អាចបង្ហាញព័ត៌មានដែលទទួលបានពីការអនុវត្តច្បាប់នេះដល់ក្រសួងស្ថាប័នជាតិ ឬទីភ្នាក់ងារឬស្ថាប័នអន្តរជាតិ ក្នុងគោលបំណងពង្រឹងការអនុវត្តច្បាប់ ការត្រួតពិនិត្យឬនិយ័តកម្ម។

**មាត្រា១៨ .- លិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តច្បាប់**

បែបបទនីតិវិធីនៃការប្រឆាំងហិរញ្ញប្បទានការរីកសាយភាយអាវុធមហាប្រល័យ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ក្រសួងយុត្តិធម៌អាចចេញសេចក្ដីណែនាំដល់បុគ្គលឬអង្គភាពមិនមែនជាបុគ្គលរាយការណ៍ក្នុងការអនុវត្តច្បាប់នេះ។

ក្រសួង ស្ថាប័នត្រួតពិនិត្យអាចចេញសេចក្ដីណែនាំដល់បុគ្គលរាយការណ៍សម្រាប់គោលបំណងនៃការអនុវត្តច្បាប់នេះ។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**មាត្រា១៩ .- បទល្មើសនៃការបំពានសេចក្ដីសម្រេចបង្កក**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត ជនណាដែលមិនអនុវត្តតាមសេចក្ដីសម្រេចរបស់តុលាការដូចមានចែងក្នុងមាត្រា៦នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០ ០០០ ០០០(ម្ភៃលាន)រៀល ទៅ ៥០ ០០០ ០០០(ហាសិបលាន)រៀល។

**មាត្រា២០ .- បទល្មើសនៃការប្រគល់ទ្រព្យសម្បត្តិ**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត ជនណាប្រគល់ទ្រព្យសម្បត្តិទាំងអស់ឬមួយផ្នែក ទោះដោយផ្ទាល់ឬដោយប្រយោលក្ដី ឬប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះជាផលប្រយោជន៍ដល់បុគ្គលឬអង្គភាព ដូចមានចែងក្នុងមាត្រា១០នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ៥០ ០០០ ០០០(ហាសិបលាន)រៀល ទៅ ២០០ ០០០ ០០០(ពីររយលាន)រៀល។

**មាត្រា២១ .- បទល្មើសនៃការបំពានកាតព្វកិច្ចរាយការណ៍**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត ជនណាមិនបានរាយការណ៍ស្របតាមមាត្រា១២ និងមាត្រា១៣នៃច្បាប់នេះ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ចំនួន ១០០ ០០០(មួយសែន)រៀល ទៅ ១ ០០០ ០០០(មួយលាន)រៀល។

# ឧបសម្ព័ន្ធ

- សេចក្តីសម្រេចចិត្តលេខ ១៧១៨ ឆ្នាំ២០០៦ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី១៤ ខែតុលា ឆ្នាំ២០០៦)
- សេចក្តីសម្រេចចិត្តលេខ ១៧៣៧ ឆ្នាំ២០០៦ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៦)
- សេចក្តីសម្រេចចិត្តលេខ ១៨៧៤ ឆ្នាំ២០០៩ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៩)
- សេចក្តីសម្រេចចិត្តលេខ ២០៨៧ ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី២២ ខែមករា ឆ្នាំ២០១៣)
- សេចក្តីសម្រេចចិត្តលេខ ២០៩៤ ឆ្នាំ២០១៣ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៣)
- សេចក្តីសម្រេចចិត្តលេខ ២២៣១ ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥)
- សេចក្តីសម្រេចចិត្តលេខ ២២៧០ ឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦)
- សេចក្តីសម្រេចចិត្តលេខ ២៣២១ ឆ្នាំ២០១៦ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦)
- សេចក្តីសម្រេចចិត្តលេខ ២៣៧១ ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៧)
- សេចក្តីសម្រេចចិត្តលេខ ២៣៧៥ ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៧)
- សេចក្តីសម្រេចចិត្តលេខ ២៣៩៧ ឆ្នាំ២០១៧ របស់ក្រុមប្រឹក្សាសន្តិសុខ (អនុម័តនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១៧)
- សេចក្តីសម្រេចចិត្តបន្តបន្ទាប់ក្រោយចេញសេចក្តីសម្រេចចិត្តខាងលើ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា២២ .-** ការទទួលខុសត្រូវរបស់នីតិបុគ្គល

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា១៩នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣០ ០០០ ០០០(សាមសិបលាន)រៀល ទៅ ១០០ ០០០ ០០០(មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២០នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ ៤០០ ០០០ ០០០(បួនរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២១នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣០ ០០០ ០០០(សាមសិបលាន)រៀល ទៅ ១០០ ០០០ ០០០(មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី៨
## អវសានប្បញ្ញត្តិ

**មាត្រា២៣ .-** និរាករណ៍

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៤ .-** ការប្រកាសឱ្យប្រើ

ច្បាប់នេះត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៧ កើត ខែ អាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២០

នស/រកម.០៦២០-០១២

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**